# របាយការណ៍ស្ដីពី
# លទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣
# របស់ក្រុមជំនួយការចុះមូលដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ

## សេចក្តីផ្តើម

ដើម្បីគាំទ្រ និងរួមចំណែកជំរុញការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងដើម្បីលើកកម្ពស់ កិច្ចសហការសម្របសម្រួលក្នុងការដោះស្រាយបញ្ហានានាបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋតាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាលកម្ពុជា។

## I. សមិទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០២២នេះ លេខាធិការដ្ឋានក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលរបាយការណ៍ពីមន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី ខេត្ត មានសំណើ ចំនួន ៤៦ ករណី ក្នុងនោះក្រសួងដោះស្រាយបាន ចំនួន ១៤ ករណី និងពុំទាន់បានដោះស្រាយចំនួន ៣២ ករណី មានដូចខាងក្រោម ៖

### ក. ករណីបានដោះស្រាយចំនួន ១៤

- **ខេត្តកំពត មាន ៩ ករណី ៖**
  - ប្រជាពលរដ្ឋនៅភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច គោរពស្នើសុំ៖ ជួសជុលផ្លូវកៅស៊ូប្រវែង ៥០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិកំពង់ចិន ឃុំស្នឹងកែង ស្រុកទឹកឈូ គោរពស្នើសុំ៖ ជួសជុលផ្លូវភូមិកំពង់ចិនទៅតំបន់ដំរីផុង ប្រវែង ៦០០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិដានគោមខាងជើង ឃុំដានគោម ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ជួសជុលផ្លូវលំ ១ខ្សែ ប្រវែង ៣០០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិអង្គជោតិ ឃុំចំប៉ី ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ប្រវែង ២០០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិអូរស្លែង ឃុំដំណាក់កន្ទួតខាងជើង ស្រុកកំពង់ត្រាច គោរពស្នើសុំ៖ ផ្លូវក្រួសក្រហម ប្រវែង ៨០០ម៉ែត្រ ទទឹង ៥ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិកោះម៉ាក់ប្រាង្គ ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច គោរពស្នើសុំ៖ ផ្លូវបេតុង ចូលវត្តអង្គកកោះ ទំហំ ៧ម៉ែត្រ ប្រវែង ៣៥០០ ម៉ែត្រ

- ប្រជាពលរដ្ឋនៅភូមិបុះត្របែក ឃុំត្រពាំងព្រីង ស្រុកទឹកឈូ គោរពស្នើសុំ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម ១ខ្សែ ប្រវែង៧០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ គោរពស្នើសុំ៖ សាងសង់ផ្លូវក្រាលកៅស៊ូ ប្រវែង ៦៤០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិត្រពាំងកញ្ចែត ឃុំកំពង់សំរោង ស្រុកទឹកឈូ គោរពស្នើសុំ៖ ដាក់លូបង្ហូរទឹកស្អុយ និងសុំជួសជុលផ្លូវឡើងវិញប្រវែង ១៥០០ម៉ែត្រ។

➢ **ខេត្តសៀមរាប មាន ០១ ករណី ៖**
- ប្រជាពលរដ្ឋនៅភូមិសែនជ័យ ឃុំកន្ទួត ក្រុងសៀមរាប គោរពស្នើសុំ៖ ជួសជុលផ្លូវជីសក្រាលក្រួសក្រហមចំនួន ៣ខ្សែ សរុបប្រវែង ៧៣គីឡូម៉ែត្រ

➢ **ខេត្តត្បូងឃ្មុំ មាន ០៣ ករណី ៖**
- ប្រជាពលរដ្ឋនៅភូមិព្រៃកំពែង ឃុំតំបែរ ស្រុកតំបែរ គោរពស្នើសុំ៖ សាងសង់ផ្លូវក្រាលក្រួសក្រហម ០១ខ្សែប្រវែង ១០០០ ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិ១២ ឃុំក្រូចឆ្មា-ស្វាយឃ្លាំង-ប៊ុស២ ស្រុកក្រូចឆ្មារ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលកៅស៊ូពីរជាន់
- ប្រជាពលរដ្ឋនៅភូមិខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ គោរពស្នើសុំ៖ លូមូលចំនួន ៣កន្លែង។

➢ **ខេត្តស្វាយរៀង មាន ០១ ករណី ៖**
- ប្រជាពលរដ្ឋនៅភូមិនរាទេន-ចំបក់-ឈើទាល-ឈូកស ឃុំឈើទាល ស្រុកស្វាយជ្រំ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលខ្សាច់ក្នុំ ១ខ្សែប្រវែង ៦៨០០ម៉ែត្រ។

**ខ. ករណីពុំទាន់បានដោះស្រាយចំនួន ៣២**

➢ **ខេត្តកំពត មាន ១៣ ករណី ៖**
- ប្រជាពលរដ្ឋនៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ គោរពស្នើសុំ៖ ជួសជុលផ្លូវកៅស៊ូ ១ខ្សែប្រវែង ២៥០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិមាត់៣ម ឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលថ្មមិច ១ខ្សែប្រវែង ៣០០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិស្បូវអណ្តែត ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ប្រវែង ២០០០ ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិព្រៃឈើទាល ឃុំអង្គរភ្នំតូច ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រួសក្រហម ប្រវែង ១២០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិព្រៃឈើទាល ឃុំអង្គរជ័យ ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ១ខ្សែប្រវែង ២៥០០ ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិគោចិនលែង ឃុំថ្មី ស្រុកទឹកឈូ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ប្រវែង ៧០០០ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិត្រពាំងត្នោត ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ផ្លូវក្រាលក្រួសក្រហម ប្រវែង ៦០០ ម៉ែត្រ

- ប្រជាពលរដ្ឋនៅភូមិត្រពាំងត្នោត ឃុំដំបូកខ្ពស់ ស្រុកអង្គរជ័យ គោរពស្នើសុំ៖ ផ្លូវក្រាលក្រួសក្រហម ប្រវែង ៧០០ ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិត្រពាំងធំ ឃុំជុំគ្រៀល ស្រុកទឹកឈូ គោរពស្នើសុំ៖ ដាក់លូសងខាងផ្លូវបេតុងប្រវែង ១២៥០ម៉ែត្រ ទទឹង៤ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ គោរពស្នើសុំ៖ ដាក់លូផ្លូវបេតុង ខាងលិចវត្តជុំគ្រៀល
- ប្រជាពលរដ្ឋចំនួន ១១គ្រួសារនៅភូមិច្បារអំពៅ ឃុំព្រៃថ្នង ស្រុកទឹកឈូ គោរពស្នើសុំ៖ បង្គន់អនាម័យ ១១កន្លែង
- ប្រជាពលរដ្ឋចំនួន ០៩គ្រួសាររស់នៅភូមិច្បារអំពៅ ឃុំព្រៃថ្នង ស្រុកទឹកឈូ បានគោរពស្នើសុំ៖ អណ្តូងស្នប់ទឹកស្អាត ០៩កន្លែង
- ប្រជាពលរដ្ឋនៅភូមិគក ឃុំម្រោម ស្រុកអង្គរជ័យ គោរពស្នើសុំ៖ អណ្តូងស្នប់ទឹកស្អាត ០១កន្លែង។

➢ **ខេត្តសៀមរាប មាន ០៤ ករណី ៖**

- ប្រជាពលរដ្ឋនៅភូមិស្រណាល ឃុំស្រណាល ស្រុកក្រឡាញ់ គោរពស្នើសុំ៖ ផ្លូវក្រាលកៅស៊ូ ២ជាន់ ប្រវែង ២៥គីឡូម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិគោកយាង ឃុំសែនសុខ ស្រុកក្រឡាញ់ គោរពស្នើសុំ៖ ផ្លូវក្រាលកៅស៊ូ ២ជាន់ ប្រវែង ១៤គីឡូម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិក្បី ឃុំសែនសុខ ស្រុកក្រឡាញ់ គោរពស្នើសុំ៖ ផ្លូវក្រាលកៅស៊ូ ២ជាន់ ប្រវែង ៥គីឡូម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិរាជជន្ទល់ ឃុំស្រែខ្វាវ ស្រុកវ៉ារិន គោរពស្នើសុំ៖ ផ្លូវចាក់បេតុង ០១ខ្សែ ប្រវែង ៦ ៥០០ គីឡូម៉ែត្រ ។

➢ **ខេត្តព្រះវិហារ មាន ០៥ ករណី ៖**

- ប្រជាពលរដ្ឋនៅភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន ឃុំស្រអែម ស្រុកជាំក្សាន្ត គោរពស្នើសុំ៖ ជួសជុលស្ពានបេឡេគ៏ចំនួន២ ប្រវែងសរុប ៣៦,៨ ម
- ប្រជាពលរដ្ឋនៅភូមិសែនជ័យ-តេជោបុស្សស្បូវ ឃុំស្រអែម ស្រុកជាំក្សាន្ត គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ២២៥ម និងលូចំនួន ២កន្លែង។
- ប្រជាពលរដ្ឋនៅភូមិធម្មជាតិសម្តេចតេជោហ៊ុនសែន ឃុំស្រអែម ស្រុកជាំក្សាន្ត គោរពស្នើសុំ៖ ជួសជុលស្ពានបេឡេគ៏ចំនួន ០២ខ្សែ ប្រវែង ៣៦,៨ ម៉ែត្រ
- ប្រជាពលរដ្ឋនៅភូមិសែនជ័យ ឃុំស្រអែម ស្រុកជាំក្សាន្ត គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ២២៥ម៉ែត្រ និងលូ ២កន្លែង
- ប្រជាពលរដ្ឋនៅភូមិពាក់ស្បែក-ស្រែ-ស្វាយ ឃុំរំដោះស្រែ ស្រុកជាំក្សាន្ត គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ១៩ ១០០ម៉ែត្រ ស្ពាន ១កន្លែង និងលូ ៥កន្លែង។

- **ខេត្តត្បូងឃ្មុំ មាន ០១ ករណី ៖**
  - ប្រជាពលរដ្ឋនៅភូមិដីប្លុក-ក្បាលស្លែង ឃុំជាំក្រវៀន ស្រុកមេមត់ គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ១ខ្សែប្រវែង ៦ ០០០ម៉ែត្រ។
- **ខេត្តមណ្ឌលគិរី មាន ០៧ ករណី ៖**
  - ប្រជាពលរដ្ឋនៅភូមិពូហ្យាម ឃុំសែនមនោរម្យ ស្រុកអូររាំង គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលល្បាយថ្មភ្នំ ក្នុងក្រុមចុងរ៉ាង ប្រវែង ៣ ០០០ម៉ែត្រ និងស្ពានឈើឆ្លងកាត់អូរខ្វង់ ១កន្លែង ប្រវែង ៦០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិពូហ្យាម ឃុំសែនមនោរម្យ ស្រុកអូររាំង គោរពស្នើសុំ៖ បង្គន់អនាម័យចំនួន ៧០
  - ប្រជាពលរដ្ឋនៅភូមិពូហ្យាម ឃុំសែនមនោរម្យ ស្រុកអូររាំង គោរពស្នើសុំ៖ អណ្តូងទឹកចំនួន ០២។
  - ប្រជាពលរដ្ឋនៅភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង គោរពស្នើសុំ៖ ជួសជុលផ្លូវលំ ០១ខ្សែ ដែលតភ្ជាប់ពីផ្លូវជាតិលេខ ៧៦A ប្រវែង ៤ ០០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិមេប៉ៃ ឃុំពូជ្រៃ ស្រុកពេជ្រាដា គោរពស្នើសុំ៖ ជួសជុលផ្លូវលំ ០១ខ្សែ ប្រវែង ៥ ០០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិពូតាង ឃុំពូជ្រៃ ស្រុកពេជ្រាដា គោរពស្នើសុំ៖ ជួសជុលផ្លូវលំ ០១ខ្សែ ប្រវែង ១០ ៥០០ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិមេប៉ៃ ឃុំពូជ្រៃ ស្រុកពេជ្រាដា គោរពស្នើសុំ៖ អណ្តូងស្នប់ចំនួន ៥។
- **ខេត្តស្វាយរៀង មាន ០២ ករណី ៖**
  - ប្រជាពលរដ្ឋនៅភូមិដីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៩ ០០០ ម៉ែត្រ
  - ប្រជាពលរដ្ឋនៅភូមិក្រញូង-បឹងកេ ឃុំមុខដា-ម្រាម ស្រុករមាសហែក គោរពស្នើសុំ៖ ជួសជុលផ្លូវក្រាលក្រួសក្រហម ០១ខ្សែ ប្រវែង ៧ ៣០០ ម៉ែត្រ។

## II. បញ្ហាប្រឈម

- ការធ្វើវិចារណកម្មចំណាយថវិកាថ្នាក់ជាតិ ដោយជំរុញឱ្យគ្រប់ក្រសួង ស្ថាប័ន និងអង្គភាព ចូលរួមពង្រឹងប្រសិទ្ធភាពចំណាយក្នុងបុព្វហេតុសន្សំធនធាន ដើម្បីបង្វែរថវិកាមកដោះស្រាយបញ្ហាជាអាទិភាពដែលរងផលប៉ះពាល់អវិជ្ជមានដោយសារជំងឺកូវីដ-១៩ ធ្វើឱ្យកាត់បន្ថយថវិកាវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ
- មិនទាន់ឆ្លើយតបតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋានបានទាន់ពេលវេលា។

## III. ទិសដៅការងារបន្តឆ្នាំ២០២៣

- បន្តសហការដោះស្រាយបញ្ហាប្រឈមនិងការលំបាកនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន

- បន្តលើកកម្ពស់ការទទួលខុសត្រូវតាមអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទតាមរយៈការត្រួតពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធី គម្រោង និងផែនការសកម្មភាពនានានៅតាមមូលដ្ឋាន
- កៀរគរធនធានពីប្រភពនានា ដើម្បីចូលរួមដោះស្រាយជីវភាពប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន
- បន្តសហការជំរុញ និងលើកកម្ពស់គណនេយ្យភាពរបស់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានឱ្យមានប្រសិទ្ធភាព។

**សេចក្តីសន្និដ្ឋាន**

តាមរយៈការបង្កើតក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការដោះស្រាយនូវ សំណើ សំណូមពរ ប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយក៏បានចូលរួមការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦ នៃរដ្ឋសភាផងដែរ។